ព្រះរាជបណ្ណាល័យកម្ពុជា

# កម្ពុជសុរិយា

## សៀវភៅចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

## ឆ្នាំគម្រប់បី

ខែ ៨

ក្រុងភ្នំពេញ

រោងពុម្ពរាជការ គុវែរណើម៉ង្គ

គ្រិ. ឆ្នាំ ១៩៣០

ពុ. ស. ២៤៧៣

អ្នកទទួលខុសត្រូវ ជុំ-មៅ

# បញ្ជីរឿង

ទំព័រ

១- រឿងមិលិន្ទបញ្ហា ព្រះគ្រូវិមលបញ្ញា អ៊ុម-ស៊ូរ អាចារ្យនៅព្រះរាជបណ្ណាល័យកម្ពុជា ប្រែពីបាលីមកជាភាសាខ្មែរ (ត) . . . . .

២- គតិលោក ឬ ច្បាប់ទូន្មានខ្លួន ឧកញ៉ាសុត្តន្តប្រីជា ឥន្ទ រៀបរៀង (ត) ( គតិលោក និង មិលិន្ទបញ្ហា មិនបានចុះក្នុងនេះទេ ព្រោះមានបោះពុម្ពសៀវភៅដោយឡែកហើយ) . . . . . . .

៣- ប្រវត្តិរបស់វត្តពោធិវាល (បាត់ដំបង) អាចារ្យ អ៊ីវ-ទូត ចៅអធិការវត្តនេះ រៀបរៀង (ត) . . . . . . . ២១៧

៤- រឿងមហាភារត ព្រះមហាពិទូរក្រសេម គន្ថរចនបណ្ឌិត នៅព្រះរាជបណ្ណាល័យកម្ពុជា ប្រែពីភាសាសៀមមកជាភាសាខ្មែរ (ត) . . . ២៣១

៥- សេចក្ដីស្រង់ធម៌ទេសនាយ៉ាងសង្ខេប របស់លោកកំម៉ង់ដង្គូរប៉ែរ ដែលសម្ដែងនៅមន្ទីរពុទ្ធសាសនបណ្ឌិត កាលពីថ្ងៃ ១៨ សេបតមឆ្នាំ ១៩៣០ ក្រុមការ ជុំ-ម៉ៅ ប្រែជាភាសាខ្មែរ . . . . . . ២៤៧

# ប្រវត្តិរបស់វត្តពោធិវាល

ឃុំវត្តសង្កែ ខេត្តបាត់ដំបង

ចៅអធិការអ៊ី-ខួត រៀបរៀង

(៣)

---

លោកគ្រូព្រះឧបជ្ឈាយ៍ សំ បានសាងព្រះពុទ្ធរូបមួយអង្គនៅឯលិច ឯត្បូងព្រះដីវធំ គូនឹងព្រះ ដន្ទោ ហ៊ាន ឧបាសិកា ទេស ដែលសាងអំពី ឆ្នាំជូត ពុទ្ធសករាជ ២៤៤៣ ។

ឧបាសក ហ៊ុល ឃោសនាសាងព្រះទ្រង់គ្រឿងមួយអង្គនៅឯកើត ឯត្បូងព្រះដីវធំ គូនឹងព្រះសិរីទ្ធិលោកសម្តេច ស្វា វត្តកណ្តាល ព្រះលោកសម្តេច ស្វា នេះ កាលពីដើមមិនបានទ្រង់គ្រឿងទេ លោកហែមកដាក់វត្តពោធិវាល តាំងតែអំពីពុទ្ធសករាជ ២៤១៨ ។

ដល់មកឧបាសក ហ៊ុល សាងព្រះទ្រង់គ្រឿង ទើបបានប្រដាប់គ្រឿងឡើង ឲ្យត្រូវគូនឹងព្រះពុទ្ធរូបរបស់ឧបាសក ហ៊ុល គ្រូសូត្រ ខួត សាងព្រះអង្គឈើមួយអង្គនៅខាងត្បូងជាគូនឹងព្រះចាស់ ដែលនាយ យឹម សាងអំពីពុទ្ធសករាជ ២៤៤៧ បាត់ធ្វើការប្រដាប់ក្បាច់តាំងបល្ល័ង្កតាំងគ្រឹះក្រោម អស់ជាទ្រព្យ គឺឧបាសិកា ធិម ចេញមួយពាន់ពីររយរៀល ឧបាសក ហ៊ុល ឃោសនាជួយក្នុងការបញ្ចក្កមួយរយ ឃោសនាសាងព្រះទ្រង់គ្រឿងមួយរយម្ភៃរៀល ព្រះលោកគ្រូឧបជ្ឈាយ៍ សំ សាងពីររយ

រៀល ព្រះដែលគ្រូសូត្រ ទួត សាងប៉ែតសិបរៀល រួមដែលសាងក្នុង គ្រានោះអស់ជាប្រាក់ ១ ពាន់ប្រាំពីររយរៀល សាងរួចស្រេចនៅថ្ងៃ ១៥ កើតខែចេត្រឆ្នាំរោងអដ្ឋស័ក ពុទ្ធសករាជ ២៤៥៧ ។

លុះដល់មកឆ្នាំមមី ឧបាសិកា ធិម ធ្វើបុណ្យបិតាបានសាងប៉ាតាមួយ អស់ជាប្រាក់ប្រាំពីររយរៀល ។ ឯសាស្ត្រាប្រែរយក្នុងវត្តពោធិវាលតាំង តែអំពីកិត្តិ ញ៉ក យកទៅឲ្យអន្ទកាយ សល់នៅក្នុងវត្តពោធិវាលតិចណាស់ ។

ទើបគ្រូសូត្រ ទួត និយាយឲ្យឧបាសិកា ធិម ចេញទ្រព្យសាង ឧបា-សិកា ធិម ក៏មានសទ្ធាចេញទ្រព្យឲ្យសាងជាច្រើនគម្ពីរ គម្ពីរសារត្ថសង្គហ ប្រែមួយចប់ វិសុទ្ធិមគ្គប្រែមួយគម្ពីរ បឋម-ទុតិយ-តតិយ-សង្គាយនា ១គម្ពីរ ព្រះធម្មបទប័នបាយប្រែ ១ ចប់ ព្រះធម្មបទបាលីមួយគម្ពីរ មង្គលទីបនីបាលី មួយគម្ពីរ សតិបដ្ឋានប្រែមួយគម្ពីរ ចតុរារិយសច្ចមួយគម្ពីរ មហាជាតក៍ប្រែ មួយគម្ពីរ ទសជាតក៍ ប្រែមួយគម្ពីរ សព្វទានប្រែមួយគម្ពីរ ១៥ កោក ព្រះបឋមសម្ពោធ ប្រែមួយគម្ពីរ ១៥ កោក រួមគម្ពីរដែលសាងទាំងប៉ុន្មាន គិតជាប្រាក់ ៨៥០ រៀល ឯសាមណេរ សុជ ដែលចូលទៅរៀនព្រះត្រៃ បិដកឯស្រុកសៀម ក៏ខំតាំងពីព្យាយាមរៀន ដល់អាយុកំណត់ ២១ ឆ្នាំ ក៏ឧបសម្បទឯស្រុកសៀម ។

លុះដល់មកឆ្នាំមមែឯកស័កពុទ្ធសករាជ ២៤៦២ គ្រូសូត្រ ទួត ទៅ ទទួលលោកអាចារ្យ សុជ ចូលមកនៅវត្តពោធិវាលវិញ លោកអាចារ្យ សុជ ក៏តាំងបង្ហាញព្រះត្រៃបិដកមក ។

លុះដល់មកឆ្នាំកេឧបាសិកា ធិម គិតឃើញថា សាលាដែលលោកព្រះគ្រូ សន សាងនោះចាស់គ្រាំគ្រាណាស់ ទើបនិយាយនឹងជាង កុយ ឲ្យចាត់ចែងធ្វើ ជាង កុយ ក៏រ៉ាប់សទ្ធាកំឡាំងធ្វើមិនយកឈ្នួល ចាត់កេប្រដាប់បាន តាំងលើកសាលានៅថ្ងៃ ៤ រោច ខែពិសាខ ឆ្នាំកាត្រីស័ក ពុទ្ធសករាជ ២៤៦៤ សាលាដែលឧបាសិកា ធិម សាងអស់ជាប្រាក់មួយពាន់ពីររយរៀល លុះស្រេចសាលាលោកអាចារ្យ សុដ ពិគ្រោះនឹងគ្រូសូត្រ ទួត ចង់សាងហោត្រៃនឹងតម្កល់ព្រះត្រៃបិដក ដោយការសមគួរ លុះពិគ្រោះព្រមគំនិតគ្នា ទើបយកសេចក្តីនេះប្រាប់ដល់ឧបាសកឧបាសិកា ព្រមទាំងឧបាសិកា ធិម ជាឧបដ្ឋាក គាត់ក៏សោមនស្សចេញបួនរយរៀល អ្នកហ្វូងនិរន្ទ អ្នកសិការ ទូជ មួយរយហាសិបរៀល ដែលចេញជាងនោះច្រើនឈ្មោះ រួមទាំងអស់គ្នាបានពីរពាន់រៀល លុះកេគ្រឿងប្រដាប់បានតាំងលើកហោត្រៃនៅថ្ងៃ ១០ កើត ខែស្រាពណ៍ ឆ្នាំកាត្រីស័ក ពុទ្ធសករាជ ២៤៦៤ ។

លុះមកដល់ថ្ងៃពុធ ១០ រោច ខែអស្សុជ លោកគ្រូព្រះឧបជ្ឈាយ៍ សំ លោកកើតរោគក្អកឈាមមក ២០ ឆ្នាំហើយ ដល់មកក្នុងថ្ងៃនោះ វេលាម៉ោង ១២ អធ្រាត្រ លោកក្អកឈាមក៏បណ្ដាលឡើងមិនមានស្រាក ដល់ម៉ោង ៤ ទៀបភ្លឺ លោកក៏ទទួលអនិច្ចធម្ម អាយុលោកបាន ៨២ ឆ្នាំ វស្សា ៥៨ គ្រូសូត្រ ទួត ព្រមទាំងសិស្សទាំងអស់ក៏ប្រជុំគ្នា ចាត់ធ្វើបុណ្យឈាបនកិច្ចនៅថ្ងៃ ៣ កើត ខែ កត្តិក ឆ្នាំកា លុះធ្វើបុណ្យស្ទួរេច ទើប

ព្រះរាជាគណៈ ព្រមទាំងជំនុំសង្ឃនិងឧបាសកឧបាសិកា ប្រជុំតាំងលោកគ្រូសូត្រ ទួត ជាចៅអធិការនៅថ្ងៃអាទិត្យ ៦ កើត ខែកត្តិក ឆ្នាំរកាត្រីស័ក ពុទ្ធសករាជ ២៤៦៤ ត្រូវនឹងថ្ងៃ ២០ ខែណូវែម ឆ្នាំ ១៩២១ ។

ចៅអធិការ ទួត ក៏ទទួលគ្រប់គ្រងវត្តពោធិវាលមក ឯហោត្រៃចាស់ធ្វើស្រេចក៏បញ្ជូនព្រះត្រៃបិដកព្រមទាំងទូទៅតម្កល់លើហោត្រៃថ្មី ចៅអធិ-ការទួតក៏ប្រគល់កិច្ចធុរក្នុងហោត្រៃឲ្យលោកអាចារ្យ សុជ គ្រប់គ្រងលោកអាចារ្យសុជ ក៏តាំងព្យាយាមបង្ហាញព្រះត្រៃបិដក ហើយថែរក្សាព្រះបិ-ដក ដោយការមាំមួនក្នុងឆ្នាំនោះ ចៅអធិការ ទួត បានចាត់សាងព្រះចេតិយ ១ ខាងទិសនិរតីក្នុងកំផែងព្រះវិហារ ព្រះចេតិយនោះទំហំជើងក្រោម ៤ ម៉ែត្រ ៤ ជ្រុង កំពស់៩ម៉ែត្រ ៦៥សង្ទីម៉ែត្រ បញ្ចុះអដ្ឋិធាតុលោកគ្រូឧបជ្ឈាយ៍ សំ ព្រមទាំងញោមលោកទាំងពីរ បានចាត់ធ្វើបុណ្យបញ្ចុះជាស្រេច នៅថ្ងៃ ១កើត ខែកត្តិក ឆ្នាំចត្វាស័ក ពុទ្ធសករាជ២៤៦៥ ក្នុងគ្រានោះចៅអធិការ ទួត គិតឃើញដល់ឈ្មោះវត្ត ថាដែលឈ្មោះវត្តពោធិវាលនេះ ព្រោះពីដើមមានដើមពោធិ ឥឡូវនេះពោធិនោះស្គុតទៅយូរឆ្នាំហើយ គួរតែនិងឲ្យមានពោធិ ១ ដើមជាដំណាង ក៏បណ្ដាលឲ្យនឹកដល់ព្រះពុទ្ធដីកាដែលសម្ដែងក្នុងមហាបរិនិព្វានសូត្រ ក្នុងគម្ពីរទីឃនិកាយប្រោសព្រះអានន្ទ កាលព្រះសម្មាសម្ពុទ្ធទៀបនឹងចូលព្រះនិព្វាន ព្រះអានន្ទទូលសួរថា : បើព្រះពុទ្ធអង្គទ្រង់បរិនិព្វានហើយ តើពុទ្ធបរិស័ទរាល់គ្នានឹងទៅបដិបត្តិអ្នកឯណាឲ្យជាទីចម្រើនចិត្តដូចព្រះសម្មាសម្ពុទ្ធ ទើប

ព្រះពុទ្ធអង្គទ្រង់ត្រាស់ថាអានន្ទ បើតថាគតនិព្វានទៅហើយទីសំវេជនិយស្ថានមាន ៤ ឋាន គឺទីដែលតថាគតប្រសូត ១ ទីព្រះពោធិព្រឹក្ស ដែលតថាគតត្រាស់ ១ ទីដែលតថាគតសម្តែងធម្មចក្កប្បវត្តនសូត្រ ១ ទីដែលតថាគតនិព្វាន ១ ទាំង ៤ ស្ថាននេះ បុគ្គលឯណាបានគោរពនមស្សការរលឹកនឹកដល់តថាគត បុគ្គលនោះកាលបើដល់មរណភាពនឹងបានចូលទៅកាន់សុគតិភព គឺសួគ៌ទេវលោក គិតឃើញដូចនេះក៏បង្កើតជ្រះថ្លាចង់បានពូជពោធិព្រឹក្សយកមកដាំក្នុងវត្ត ក៏ទទួលបានដំណឹង ថាពោធិដែលព្រះបាទទេវានម្បិយតិស្ស បានឲ្យសាកពោធិព្រឹក្សអំពីពោធិគយាត្រង់កន្លែងដែលព្រះពុទ្ធត្រាស់នោះយកមកដាំក្នុងលង្កា លុះឯក្រោយសម្តេចព្រះនរោត្តម ព្រះចៅក្រុងកម្ពុជាបានពូជ អំពីលង្កាមកដាំក្នុងវត្តបទុមវតីក្រុងភ្នំពេញទើបទៅគិតនឹងព្រះមហាពជធម្ម ឌិត ៗ បានទៅនិយាយនឹងព្រះគន្ធមុនី វត្តបទុម ឲ្យសាក លុះសាកបានទៅអធិការ ទួត ក៏បាត់ធ្វើដើររចនាក្បាច់បិទមាសប្រដាប់កញ្ចក់បានស្រេច ទើបឲ្យលោកអាចារ្យសុជ ទៅទទួលពីព្រះគន្ធមុនី ៗ ក៏ចាក់ផ្ទេរដាក់ជើងថ្មី ហើយលើកទៅតម្កល់ក្នុងព្រះវិហារ និមន្តព្រះភិក្ខុសង្ឃ មានព្រះមង្គលទេព្វាចារ្យ ព្រះសង្ឃនាយកជាប្រធាន ចម្រើនពុទ្ធមន្តថ្វាយជ័យមង្គលស្រេច ក៏ដង្ហែព្រះពោធិព្រឹក្សចុះកប៉ាល់ លុះដល់បាក់ព្រា លោកគ្រូសូត្រ ជួរ វត្តស្តីព្រម ទាំងឧបាសក ឧបាសិកាយកទូកជាច្រើនទៅទទួលអំពីកប៉ាល់ ដង្ហែចូលមកក្នុងស្រុកបាត់ដំបង ។

ឯព្រះឧបជ្ឈាយ៍និងព្រះសមុហ៍វត្តឯករង្សី ព្រមទាំងឧបាសកឧបាសិកា ក៏មានបង្គារៀបរណ្ដាប់ធ្វើមណ្ឌបនៅមុខព្រះវិហារ ហើយធ្វើតិតាទសម្ពត់អំពីមណ្ឌបរហូតដល់មាត់ស្ទឹង លុះពោធិព្រឹក្សមកដល់ ក៏ដង្ហែចូលទៅតម្កល់នៅមណ្ឌប់ក្នុងវត្តឯករង្សី ហើយចាត់ធ្វើមហាសទកិច្ចស្រេច ទើបអស់ពួកឧបាសក ឧបាសិកាទាំងខាងលើខាងក្រោមក្នុងខេត្តបាត់ដំបង ក៏សមាគមជាប្រជុំធំចាត់ទូកជាច្រើនទៅទទួលដង្ហែព្រះពោធិព្រឹក្ស អំពីវត្តឯករង្សីចូលមកក្នុងវត្តពោធិវាល នៅថ្ងៃ ១០ កើត ខែកត្តិក ឆ្នាំច ចត្វាស័ក ពុទ្ធសករាជ ២៤៦៥ ហើយចាត់ធ្វើមហាសទកិច្ចក្នុងវត្តពោធិវាលម្ដងទៀត ទើបចៅអធិការ ទួត ក៏ចាប់រៀបអិដ្ឋធ្វើជាគ្រឹះដាំព្រះពោធិព្រឹក្ស ហើយសាងព្រះពុទ្ធរូបស្ពាន់មួយអង្គ ធ្វើជាព្រះសួបតម្កល់អំពីមុខពោធិព្រឹក្សអស់ជាប្រាក់ ៥ រយរៀល លុះចាត់ធ្វើស្រេចទើបដង្ហែព្រះពោធិព្រឹក្សដាំនៅថ្ងៃសុក្រ ១២ កើត ខែចេត្រឆ្នាំកុរបញ្ចស័ក ហើយចាត់ការសម្ពោធព្រះពោធិព្រឹក្សជាឧឡារិកគំរប់ ៣ ថ្ងៃ ។

លុះដល់មកឆ្នាំជូតឆស័ក លោកចៅអធិការ ទួត គិតទិញជួសជុលព្រះវិហារ ត្បិតព្រះវិហារនោះខូចខាតជាច្រើន ទាំងសសរ ក៏ដាប់ជើងគ្រឿងលើពុកខូចជាច្រើន កំផែងក៏ស្រុតបែកប្រេះជាច្រើនអន្ទើរខ្លាំងទ្វារទាំង ៤ ក៏ខូច ដែលទើងគិតជួសជុលថ្មី គឺកាត់ជើងសសរចាស់ទាំងអស់ចេញហើយដែកស៊ីម៉ង់ត៍ វេអិដ្ឋចិន ដែលក្រាលក្នុងវិហារ យកមកក្រាលខាងក្រៅ

ហើយទិញអិដ្ឋពណ៌ក្រាលក្នុងវិហារ គ្រឿងឈើដែលខូចប៉ុន្មាន ក៏ជួសជុលថ្មីទាំងអស់ ហើយគាត់ធ្វើផ្កាយគ្រប់ល្វែង ធ្វើឈូកតាមមេជញ្ជាំងខាងលើជុំវិញ ឯកំផែងដែលខូចខាតប៉ុន្មាន ក៏ជួសជុលឡើងថ្មីក្នុងកំផែងក្រាលអិដ្ឋពេញទាំងអស់ ជើងកំផែងខាងក្រៅត្រង់ណាដែលខូច ក៏លើកដីបំពេញឡើងក្រាលអិដ្ឋជុំវិញ ហើយក្រាលជាថ្នល់ហូតដល់មកខ្លោងទ្វារក្រៅ ។

ឯក្បាច់ស៊ុមទ្វារបង្អួចនិងសន្ទឹកដែលខូចខាត ក៏ជួសជុលឡើងហើយបែកឲ្យឧបាសក-ឧបាសិកាជួយបិទមាស ១ វង់ម្នាក់ តួព្រះវិហារទាំងក្នុងទាំងក្រៅ ក៏គាត់លាបថ្នាំថ្មីឡើងហើយបិទមាសជាក្បាច់តាមសសរនិងធ្នឹម ទាំងហោជាងក៏បិទមាសឡើងជាថ្មី ឯព្រះជីធំប្រេះបែកជាច្រើនអន្លើ ក៏គាត់ជួសជុលឡើងជាថ្មី បិតធ្វើក្បាច់ជាផ្កា ហើយធ្វើជាឆ័ត្រត្រួត ជាក្បាច់បិទមាសដាក់ក្តោកបាំងអំពីលើ ឯខ្លោងទ្វារកំផែងទាំង ៤ ជះស្ទ៊ី ហ៊ុន ឧបាសិកា សិប ចេញប្រាក់មួយពាន់មួយរយឲ្យធ្វើជាថ្មី ដែលគាត់បដិសំខរណព្រះអាពមក្នុងគ្រានោះ តាំងតែអំពីឆ្នាំជូតហូតដល់ឆ្នាំខាលទើបស្រេច ឯទីព្រះអាពម នៅថ្លុកទំនាបជាច្រើនអន្លើ ត្បិតអ្នកដែលធ្វើការអំពីដើមមិនបានជាពិគ្រោះត្រូវការត្រង់ណា ក៏ជីកត្រង់-ណោះ លោកចៅអធិការនិងលោកអាចារ្យក៏បានជួយចេញថ្លៃជួលគួលីឲ្យលើកដីបំពេញឡើង ហើយឲ្យលើកជាថ្នល់មួយជុំវិញ ទាំងក្នុងទៀត

ឯណាដែលបាក់ពុកក៏ចាត់ជួសជុលឡើង នៅថ្ងៃ ១ កើតខែអាសាឍ ឆ្នាំ
ឆ្លូវ ឧបាសក អ៊ិត ឧបាសិកា ខេស នៅភូមិដូនបែនស្ទឹងចាស់
បានសាងព្រះចេតិយ៍ ១ ខាងទិសក្លៀសានបញ្ចុះអដ្ឋិមាតាបិតា ព្រះ
ចេតិយ៍នោះទទឹងជើងក្រោម ៣ ម៉ែត្រ ៣៥ សន្ទីម៉ែត្រ ៤ ជ្រុង កំពស់
៩ ម៉ែត្រ គិតជាប្រាក់អស់បីរយហាសិបរៀល ដែលរករបស់បុរាណ
តាំងជាពុទ្ធបូជាអំពីឆ្នាំឆ្លូវ ពុទ្ធស័ករាជ ២៤៦៨ លោកចៅអធិការ ទួត
បានចេញទ្រព្យបំណាយធ្វើទូតាំង ហើយយកទ្រព្យជាមរតកអំពីមាតាខ្លះ
មករៀបតាំងជាដំបូង ពួកអ្នកស្រុកឃើញក៏មានសទ្ធា អ្នកឯណាដែលមាន
របស់ចាស់ជាមរតកកេរ្តិ៍ អំពីត្រកូលមក ក៏មានសទ្ធាយកមកប្រគេនជា
ច្រើន អ្នកខ្លះដែលនៅស្តាយជាកេរ្តិ៍ លោកចៅអធិការ ទួត បានចេញ
វត្ថុផ្សេង ៗ ឲ្យជារង្វាន់ខ្លះ ហើយចុះឈ្មោះថាម្ចាស់របស់ប្រគេនក៏មាន
ដែលលោកចៅអធិការ ទួត ចាត់រកវត្ថុបុរាណតាំងជាពុទ្ធបូជាក្នុងគ្រានោះ
ដែលចេញថ្លៃធ្វើទូហើយឈ្នួលដឹកនាំរបស់អំពីចម្ងាយនិងរង្វាន់ម្ចាស់របស់
ខ្លះគិតជាប្រាក់សួនខ្ទួនមួយពាន់រៀល អ្នក សុកី អ្នក សុខ នៅស្ទឹង
ចាស់បានសាងទូធំមួយប្រគេន អស់ជាប្រាក់ប៉ែតសិបរៀល ហើយ
លោកអាចារ្យ សុជ ក៏យកចិត្តឈើឆ្កាលជួយទំនុកបម្រុងរៀបតាំងពេញ
កម្លាំង ឯចំនួនរបស់បុរាណទាំងប៉ុន្មាន មានក្នុងបញ្ជីសម្រាប់វត្តឯនោះ
ផ្សេង ៗ

ក្នុងខែចេត្រ ឆ្នាំឆ្លូវ នោះបានគិតឲ្យមានវត្ថុបច្ច័យជាប្រាក់សម្រាប់បដិសំខរណ៍ព្រះអារាម បើមានទេសនាក្នុងអារាមប្រាក់ចំណូលចែកជាពីរចំណែក មួយចំណែកសម្រាប់អារាម មួយចំណែកធម្មកថិក បើទៅសម្តែងធម៌ខាងក្រៅវត្ត វត្ថុបច្ច័យ ១០ ហូតមួយទុក ប្រាក់សម្រាប់អារាម លុះដល់មកឆ្នាំខាលលោកអាចារ្យ ឆិន្ន ថៃ យ៉ម ហែព្រះកឋិនទានមកបានបវារណាប្រាក់សម្រាប់អារាមមួយរយរៀល ហើយសាងទូមួយដាក់ក្នុងព្រះវិហារសម្រាប់អ្នកចេញចូលនមស្សការព្រះ មានសទ្ធាដាក់ចុះក្នុងទូនោះ អ្នកខ្លះដែលហែកឋិនប្តូរទៀនវស្សា មានបវារណាបច្ច័យសម្រាប់អារាមក៏មាន មានអ្នកសទ្ធាបង់រៀងឆ្នាំក៏មាន ប្រាក់សម្រាប់អារាមទាំងប៉ុន្មាននៅដៃ អាចារ្យ ពន់១ លោកអាជ្ញា ដេក១ ឧបាសក អាត់ ឧបា-សក នាល់ ១ អ្នកទាំង ៤ នេះជាអ្នកសម្រេចកិច្ចហើយអ្នកឧបត្ថម្ភគ្រា-កិបាលមេឃុំ ញ៉ិក វត្តសង្កែ ជាអ្នកជួយទំនុកបំរុងក្នុងការនេះផង លុះចាត់បដិសំខរណ៍ព្រះអារាមបានរុងរឿង ទាំងឧបាសក-ឧបាសិកា ឬទាយក-ទាយិកា ក៏កាន់តែសទ្ធា ចូលមកធ្វើបុណ្យរក្សាសីលច្រើន លើសអំពីដើម លុះដល់មកឆ្នាំខាលបញ្ចស័ក ពុទ្ធសករាជ ២៤៦៩ លោកចៅអធិការ ទួត មករំពឹងគិតថា បំណែកខាងព្រះអារាមក៏បដិសំខរណ៍បានរុងរឿងឡើងជាទីជ្រះថ្លាដល់ពុទ្ធបរិស័ទគ្រាន់បើ តែធម៌វិន័យនៅទន់ទាបនៅឡើយ ព្រោះបតិបត្តិតែតាមទម្លាប់ មិនបានជាំពឹងរកការពិត

មែនតាមព្រះពុទ្ធដីកា ដែលមានឡាក់ហ៉ាន់តាមព្រះគម្ពីរ មួយវិញទៀត ដែលគិតដល់ធម៌វិន័យតាំងតែអំពីឆ្នាំរកាត្រីស័ក ពុទ្ធស័ករាជ ២៤៦៣ មកឃើញថាភិក្ខុដែលបួស ច្បាប់ដែលជាគោលចារ៉ែកទីនព្រះវិន័យ បើមិនចេះព្រះវិន័យដូចជាមនុស្សគ្មានសម្ពត់ស្លៀក ហើយក្នុងសម័យនេះ វិន័យចេះតែខូចទៅ ព្រោះអ្នកបួសថ្មីមិនសិក្សារៀន គ្រង់ច្បាប់ព្រះវិន័យ នោះឃើញថាគួរតែនឹងឲ្យភិក្ខុសាមណេរខំសិក្សារៀនសូត្រឡើង តែក្នុងគ្រានោះ រកឱកាសពុំទាន់មាន ព្រោះក្នុងអាពមឬព្រះវិហារក៏ចាស់គ្រាំគ្រា ហើយ បើជាទីនបន្ទំឲ្យរៀនសូត្រឬប្រឹងប្រិតក្នុងផ្លូវបដិបត្តិតែម្តងក្រែងក្សាក់ផ្អើលទើបពុំបានចាត់ការពេញទី គ្រាន់តែទេសនាវិន័យពន្យល់ រាល់តែថ្ងៃឧបោសថអំពីឆ្នាំនោះមក ហើយមកមានសេចក្តីពេញចិត្តនឹងផ្លូវបដិបត្តិលោកគ្រូ គុជ លោកគ្រូ ស៊ីវ ដែលលោកបតិបត្តិបានត្រឹមត្រូវ មុខគួរឲ្យអស្ចារ្យ ត្បិតអ្នកប្រាជ្ញក្នុងគ្រានោះមានតិចណាស់ ហេតុម្តេចលោកក៏ចេះវែកញែកផ្លូវបតិបត្តិបានសមគួរតាមពុទ្ធបញ្ញត្តិ ដល់ឥឡូវនេះអ្នកប្រាជ្ញក៏មានច្រើនតែផ្លូវបតិបត្តិចេះតែជោគជ័យទៅ មួយវិញទៀត មកឃើញផ្លូវបតិបត្តិពួកលោកអ្នកប្រាជ្ញក្នុងសាលាបាលី ដែលរាជការតាំងឲ្យមានសាលាលីឡើង លោកអ្នកប្រាជ្ញជាគ្រូបង្រៀនក្នុងសាលាបាលី លោកបានជំនុំអំពីផ្លូវបតិបត្តិរកការដែលពិតមែនតាមព្រះពុទ្ធដីកា ដែលទ្រង់សម្តែងទុកក្នុងបិដកទាំងបី ក៏ឃើញថា ផ្លូវបតិបត្តិដែលធ្លាប់បតិបត្តិមក

នោះ ឃ្លៀងឃ្លាតទៅជាច្រើន ទើបលោកជ្រើសរើសរបស់ឯណាដែល ពិតបតិបត្តិឡើង របស់ឯណាដែលមិនពិតក៏ដំរុះចោលចេញ គ្រានោះ ពួកអ្នកដែលមិនបានសិក្សា ហើយប្រកាន់តែទម្លាប់ក៏កើតវិប្បលាសផ្អើល ឡើងនិន្ទាតិះដៀលមានប្រការផ្សេង ៗ ខ្ញុំក៏មានសេចក្តីងឿងឆ្ងល់នឹងទំ-នៀមទម្លាប់នេះផង មករន្ធត់នឹងលោកធម៌នេះផង ព្រោះដែលពួក សាលាបាលីតាំងបតិបត្តិឡើង នោះកើតចំរូងចំរះខ្លាំងណាស់ មួយ ទៀតក្នុងស្រុកបាត់ដំបង ពុំទាន់មានវត្តណាជ្រើសរើសរកការខុសត្រូវ នឹងបដិបត្តិ បើជានឹងតាំងបដិបត្តិតាមច្បាប់ធម៌វិន័យឡើង ខុសនឹង ទំនៀមទម្លាប់គង់នឹងមានសេចក្តីចំរូងចំរះជាមុន ក្រែងអត់ធន់នឹងពាក្យ និន្ទានោះពុំបាន ត្បិតមនុស្សល្ងង់នោះច្រើន អ្នកដែលបានសិក្សាចូល ចិត្តការខុសត្រូវនោះតិច ៗ

លុះឯក្រោយបានយកកាលាមសូត្រ ក្នុងគម្ពីរអង្គុត្តរនិកាយតិកនិបាត មកពិនិត្យតាមព្រះពុទ្ធដីកា ដែលទ្រង់ត្រាស់ប្រាប់ នឹងជនកាលាម-គោត្រនោះ ថា អ្នកដែលបដិបត្តិធម៌វិន័យ កុំគប្បីទៅប្រកាន់អាការ ១០ យ៉ាង គឺ :

ទី ១- អនុស្សវេន ប្រកាន់ជឿតាមពាក្យដែលឮតាម ៗ គ្នាមក គឺជឿតាមដោយឮដំណឹងគេនិយាយតៗ គ្នាមក មិនមានពិនិត្យពិចារណា

សាកសួរអ្នកប្រាជ្ញ ឬរៀនសូត្រឲ្យឃើញប្រាកដជាក់ច្បាស់តាមពុទ្ធវចនៈ គ្រាន់តែឮហើយក៏ជឿកាន់យកតែម្តងទៅ ។

ទី ២- បរម្បរាយ ប្រកាន់ជឿតាមពាក្យបរម្បរាយ គឺពាក្យជាលំដាប់គ្នាមក ប្រកាន់ជឿទំនៀមទំលាប់ឯណាដែលខុសអំពីពុទ្ធវចនៈដែលធ្លាប់ឃើញគេធ្វើពីដើម ៗ មក ។

ទី ៣- ឥតិកិរាយ ប្រកាន់ជឿដោយសាំងថាខ្ញុំបានឮមកដូច្នេះ ប្រាកដជាយ៉ាងនេះ ឬប្រកាន់តាមពាក្យច្រើន ដែលគេនិយាយត ៗ គ្នាមក ។

ទី ៤- បិដកសម្បទានេន ប្រកាន់ដោយសាំងក្បួនដំរាដែលខុសអំពីព្រះពុទ្ធវចន ។

ទី ៥- តក្កហេតុ ប្រកាន់ជឿដោយសេចក្តីគិតស្មាន ប្រមាណយកដោយខ្លួនឯង គឺឃើញយ៉ាងណាក៏ជឿកាន់យកយ៉ាងនោះ ស្រេចតែនឹកឃើញមិនរើសពីខុសត្រូវឡើយ ។

ទី ៦- នយហេតុ ប្រកាន់ជឿដោយគ្នេរគ្នាន់ឃើញយ៉ាងណា ក៏កាត់តម្រូវផ្សំផ្សំយកយ៉ាងនោះ ។

ទី ៧- អាការបរិវិតក្កេន ប្រកាន់ជឿដោយគិរិយាត្រិះរិះថា

ហេតុនេះល្អ គឺហេតុអ្វីៗដែលកើតឡើងហើយតែមិនមែនជាធម៌ពិត ក៏យកហេតុនោះមកផ្គូផ្គងមើល បើហេតុឯណាពេញចិត្ត ក៏ប្រកាន់ថាត្រូវជាល្អទៅ ។

ទី៨- ទិដ្ឋិនិជ្ឈានក្ខន្តិយា ប្រកាន់ជឿដោយគិតថា ហេតុនេះសមនឹងយោបល់យើង គឺហេតុអ្វីៗដែលមិនមែនជាធម៌ពិត កើតឡើងហើយត្រូវនឹងគំនិតខ្លួនដែលធ្លាប់គិតទុកមក ក៏ចូលចិត្តថា ហេតុនោះត្រូវហើយពិតហើយ បដិបត្តិកាន់យកតាមហេតុ ដែលសមនឹងយោបល់គំនិតឯងនោះទៅ ។

ទី៩- ភព្វរូបតាយ ប្រកាន់ជឿដោយគិតថាលោកនេះជាអ្នកអង់អាចចេះដឹង គួរតែយើងជឿកាន់យកតាមពាក្យលោកនេះ គឺបើមានអ្នកណាមួយគេចេះ ប្រសប់ស្ទាត់ក្នុងពាក្យសម្ដីថ្វីមាត់ពេះសម្ដីស្រួលពិរោះឥតអាក់តែពាក្យសំដីនោះ មិនមែនជាធម៌ពិតទេ ស្ដាប់ហើយក៏ប្រកាន់ជឿតាមពាក្យដែលគេប្រកបនិយាយនោះទៅ ។

ទី១០- សមណោ នោ គរុ ប្រកាន់ជឿដោយគិតថា សមណនេះជាគ្រូរបស់យើង គួរយើងកាន់យកតាមពាក្យសមណៈនេះ ដែលប្រកាន់ជឿតាមលទ្ធិគ្រូរបស់យើងនេះ បើពោះជាគ្រូនោះនិយាយខុសអំពីធម៌វិន័យ

ក៏បេះតែជឿកាន់យកតាមទាំងអស់ ពោះមានអ្នកណាមួយក្រៅអំពីគ្រូរបស់ខ្លួន គេនិយាយត្រូវតាមធម៌វិន័យរបស់ព្រះពុទ្ធជាម្ចាស់ដូចម្តេចក្តី ក៏មិនជឿ មិនកាន់យកតាម បើអ្នកឯណាប្រកាន់មាំក្នុងអាការទាំង១០ យ៉ាងនេះ ព្រះពុទ្ធសាសនា ក៏នឹងវិនាសសាបសូន្យគាប់ជុនទៅ ដោយឆាប់មិនខាន។

(មានតទៅទៀត)

# រឿងមហាភារតយុទ្ធ

ព្រះមហាពិទូរ ក្រសេម គន្ថរចនបណ្ឌិត នៅព្រះរាជបណ្ណាល័យកម្ពុជា

រៀបរៀង

(គ)

---

## ភាគជប់មួយ

### ប្រឹក្សាការស្ងប់សឹក ត្រៀមច្បាំង

ទូតរបស់យុធិស្ឋិរ មកដល់ក្រុងហស្តិនបុរ ក៏ត្រង់ចូលទៅគាល់ក្នុងព្រះទីនាំងគំនាល់ ក្រាបទូលមូលគតិទៅដូចនេះ ៖

ព្រះរាជារបស់ទូលបង្គំជាខ្ញុំ ត្រាស់ប្រើឲ្យទូលបង្គំមកក្រាបទូលព្រះអង្គជាដូចនេះ បាណ្ឌពនិងកៅរពជាបងប្អូនជីដូន ១ នឹងគ្នា ហេតុម្ដេចទើបទុរសប្ញូតកស្ត្រ បានរាជអាណាចក្រទាំងមូលគ្រប់គ្រង ឱរស បាណ្ឌុមិនបានអ្វីទីងគេ សូម្បីតែដីមួយក្ដាប់ ទុរយោធន៍គិតព្យាបាទព្រះញាតិវង្សរាល់ទិវារាត្រី ធ្វើឧបាយកលឲ្យទៅអញ្ជើញគេមកលេងស្ការក្នាល់ អ្នកស្ការសំខាន់របស់ទុរយោធន៍យកស្ការបង្កប់សំណារមកលេងដោយកលកោងទីងព្យាបាទ យុធិស្ឋិរលេងទៅដោយស្មោះចិត្តថាបងប្អូន ក៏ចាញ់រល់ៗ ក្ដារ គោងបង់ទ្រព្យស្រីគ្គារបរិវាររបស់គេទៅឲ្យទុរយោធន៍ រលីងអំពីខ្លួន ទុរយោធន៍ក៏ចេះតែកើបកោយព្រកទៅឥតមានខញ្ញាញើតដៃ

ក្នុងទីបំផុតត្រូវនិរទេសខ្លួនទៅនៅក្នុងដែនព្រៃភ្នំក្រេច  បានទទួលប្រតិបត្តិតាមខសញ្ញាយ៉ាងឧក្រិដ្ឋ  ដែលកម្រមនុស្សតាំងពួងលើផែនដីនឹងធ្វើបាន ក៏ឥឡូវនេះ គេបានប្រតិបត្តិតាមខសញ្ញានោះ ជួនបរិបូណ៌សព្វគ្រប់ហើយ ហើយបានបំភ្លេចរឿងហេតុការតាំងពួង  ក្នុងអតីតកាល  ដែលកន្លងទៅហើយ  មិនឲ្យមកកើតកោសស្រុសសន្តានចិត្ត  បើប្រគល់រាជអាណាចក្ររបស់គេ  ឲ្យគេវិញដោយស្រួល  ក៏នឹងមិនកើតកាប់សម្លាប់គ្នា  បើពាក្យពោលសុំនេះត្រឹមត្រូវតាមធម៌  ហើយត្រូវផាត់ចោល  មិនទទួលសម្រេចដោយផ្លូវយុត្តិធម៌សោត  ក៏នឹងតាំងប្រកាសសង្គ្រាមគ្នាឲ្យពេញវយៈ  ជឿទុកជាមុនថា  ពួកក្សត្រានេះនឹងខ្ទេចជាភស្មធូលី  ដែនដីតាំងនោះពួកបាណ្ឌពនឹងរឹបយកទាំងមូល ។

រាជទូតក្រាបទូលប៉ុណ្ណោះ ហើយក៏ស្ងៀមទៅចាំស្តាប់ព្រះរាជតម្រាស់តបសម្តីរបស់យុធិស្ថិរ  ដែលប្រើឲ្យរាជទូតទៅនិយាយជំនួសនោះស្តាប់ទៅត្រូវចិត្តភីស្មច្រើន  ដោយទ្រង់យល់ថាជាពាក្យត្រឹមត្រូវតាមយុត្តិធម៌ តែវាខុសក្នុងចិត្តទុរយោធន៍ឆ្ងាយកាយបានឮរាជទូតថ្លែងដូច្នេះ  ហឫទ័យទុរយោធន៍ក៏បណ្តាលខ្ញល់ខ្ញាញ់ឡើង  ត្រាស់ព្រះសូរសៀងឡើងថា អាកញ្ចះនេះបង្អាចចូលមកទទឹងមុខរាជសីហ៍ក្នុងគុហារ  ចូលប្រាប់រាជាពាក្យគម្រាមប៉ុណ្ណោះ  មិនទម្ងន់ជួនល្មមនឹងឲ្យទុរយោធន៍ព្រឺ  ជាជាងស្វាព្រាមដែលរញេញញធ្មេញឲ្យអញនោះទេ  ក្លាមាត់មិនស្មើនឹងក្លាដៃ  ក្លាមាត់

គ្រាន់តែរលាស់អណ្ដាតអួតពូកែជូនផង សូម្បីតែខ្យល់ចេទៃដែលនឹងឲ្យ មែនដល់ទៅកាប់អាវុធចូលប្រឡូងសឹកសង្គ្រាមយើង មិត្តបានចូលប្រាប់ យុធិស្ឋិរនិងបក្សពួករបស់គេថា ពាក្យគម្រោះគម្រាមជាខ្យល់ៗប៉ុណ្ណឹង មិនធ្វើឲ្យទុរយោធន៍ព្រឺពេម ដល់ទៅលើករបស់ដែលបានក្នុងកណ្ដាប់ដៃដោយជ័យជម្នះឲ្យទៅវិញទេ ចូរប្រាប់ពួកបាណ្ឌពឲ្យថែមុខទៅកាន់ព្រៃម្ដងទៀត ហើយសឹមយកថ្វាយដីកាប្រឹក្សាសុំទោសមិនព្រះពជាទុរយោធន៍ ស្រេចតែព្រះអង្គនឹងទ្រង់មេត្តាប្រោសដូចម្ដេច ។

ព្រះបាទធ្ឫតរាស្ត្រទ្រង់ហាមប្រាមព្រះរាជឱរស និងត្រាស់មកថា និងសូត្រថា ពាក្យលើសលែងស្ទើងសោកដែលទុរយោធន៍ពោលហើយ ចូរអ្នកកុំប្រកាន់កាន់យកជាអារម្មណ៍ឡើយ សម្ដីទុរយោធន៍ច្រើនតែឲ្យទោសច្រើនជាងគុណ យើងមានរាជសាសន៍ទៅដល់យុធិស្ឋិរថា យើងនឹងបញ្ជូនទូតរបស់យើងទៅជាប្រញាប់ ដើម្បីនិងចាត់ការសំរួបសំរួមទាំងសងខាង ឲ្យព្រមព្រៀងគ្នាដោយស្រួល ។

តាមសេចក្ដីបដិញ្ញាណនេះ ធ្ឫតរាស្ត្របានបញ្ជូនសេនាបតីនិងនាយសារថី សញ្ជ័យឲ្យទៅគាល់បាណ្ឌវក្សត្រិយ៍ឲ្យទូលថា ដូចនេះ បើទ្រង់ប្រាថ្នារកសេចក្ដីស្ងប់សឹក សាន្តត្រាណនិកសផងគ្នា កំអញ្ជើញទ្រង់មករកខ្ញុំ ខ្ញុំនឹងបានប្រកាសកាត់សេចក្ដីឲ្យយុត្តិធម៌ ។

កាលសញ្ជ័យមកដល់ក្រុងវិញក៏មានសេចក្តីឆ្ងល់ ដែលបានឃើញបាណ្ឌវក្សត្រិយ៍ប្រជុំពលត្រៀបត្រាមុខគួរស្ញែង ទោះដីដូចនោះក្តី គេក៏មិនបានធ្វើទុកក្នុងចិត្ត ព្រោះគេមិនបានមកក្នុងឋានៈជាចារបុរស គេមកក្នុងឋានៈជាទូត ហេតុដូចនោះទើបមិនធ្វើឲ្យគេរវល់ក្នុងរឿងត្រួតត្រាករទ័ពបាណ្ឌវក្សត្រិយ៍ គេក៏ដើរត្រង់ចូលទៅក្នុងពេងគំនាល់ លុះស្រេចការបដិសណ្ឋារហើយ ក៏ក្រាបទូលរាជសាសន៍ដល់យុធិស្ឋិរ ។

យុធិស្ឋិរ មិនសូវពេញព្រះហឫទ័យក្នុងរាជសាសន៍នោះ ដែលពោលសេចក្តីរំពេក ទើបត្រាស់ថា យើងគោរពព្រះបាទធ្ឫតរាស្ត្រណាស់ តែក្រែងថា ទ្រង់ទំនងវង្វេងជឿពាក្យឧបាយកលរបស់ឱរសទៀត សព្វថ្ងៃនេះទុរយោធន៍គិតតែនឹងក្រញិចក្រញីយើងឲ្យខូចទៅប៉ុណ្ណោះ មហារាជម្ចាស់ទ្រង់ព្រះមេត្តាប្រោសព្រះរាជទានសេចក្តីការពាររក្សាយើង ស្មើមាតាបិតារក្សាបុត្រតែមិនព្រះរាជទានឲ្យតាមពាក្យរបស់យើងប្រែកសុំ ដ៏ត្រឹមត្រូវតាមច្បាប់ខត្តិយប្រវេណី ។

ទ្រង់រំពឹងមួយស្របក់ហើយក៏ត្រាស់ទៅនឹងទូតខ្វះ ត្រាស់ឯងអើឯងខ្វះ យ៉ាងម្តេចក៏គង់កើតសង្គ្រាម មិនមានផ្លូវនឹងវេះវាងឡើយ យុត្តិធម៌ក៏ល្មមស្មើគ្នានឹងយុត្តិធម៌បាន តែដែលនឹងស៊ូអយុត្តិធម៌គង់បែរទៅអាស្រ័យកម្លាំងវត្ថុកំណាច យកមកតស៊ូ អនិច្ចា មុខគួរសង្វេគដែលពួកញាតិវង្ស គង់កាប់សម្លាប់គ្នា ស្លាប់ដូចគេហាលត្រីសំឡេងស្រី

មេម៉ាយយំខ្ទួញ និងសំឡេងក្មេងកំព្រាឥតផ្ទះសំណាក់អាស្រ័យ មុខគួរ
ស្ដាយរបស់ដែលចម្រើន ដែលលំអក្នុងព្រះនគរ នឹងវិនាសខ្ទេចខ្ទីទៅ
ក្នុងមួយរំពេច បុព្វបុរសយើង លោកបានព្យាយាមកសាងឡើង បានទទួល
សេចក្ដីនឿយលំបាកច្រើនលំដាប់បុគ្គលមកហើយ វេលានេះហើយនឹង
សាបសូន្យស្នាដៃរបស់លោក មុខគួរស្ដាយសេចក្ដីសង្ឃឹមរបស់និករ
រាស្ត្រ ដែលនឹកសង្ឃឹមលើយើងយប់ព្រឹកថា នឹងត្រឡប់ចូលព្រះនគរ
វិញដោយរៀបរយ ឥឡូវនេះគេនឹងឃើញតែយុទ្ធកម្មមុខគួរស្បើម ដើរ
ព្រាប ៗ ចូនដែនចូលទៅក្នុងសេចក្ដីវិនាសឲ្យដល់អ្នកធ្វើការសង្កត់សង្កិន
នឹងគ្រប់គ្រងមិនត្រូវតាមគន្លងធម៌ ឲ្យលុះទៅ កក្កឡកម្មទាំងពីរយ៉ាងនេះ
បានកើតឡើងដែលយើងចេញចាករដ្ឋសីមា តែវេលានេះ យើងនឹង
ក្រិស្ណជាអ្នកតំណាងទៅក្រុងហស្តិនបុរ ដើម្បីប្រឹក្សាការពារការស្រុកទេស
ឲ្យរួបរួមផង ឲ្យជាសុខសាន្តត្រាណតទៅ ចំណែកឯយើងទៅខាងនេះ
ក៏នឹងព្យាយាមឲ្យដល់ការ ដើម្បីចៀសចាកការសង្គ្រាម សូមផល
សម្រេចបូមានក្នុងកណ្ដាប់ដៃនៃលោកជាម្ចាស់ទឹកដី អ្នកជាប្រធានក្នុង
ការស្ងប់សឹកនិងការច្បាំង ៗ

សញ្ជ័យថ្វាយបង្គំលា ត្រឡប់ទៅដល់ក្នុងហស្តិនបុរ ចូលគាល់
ព្រះចៅធ្ឫតរាស្ត្រ ទូលថ្វាយក្រៃសព្រះរាជតម្រាស់របស់យុធិស្ឋិរថា ដូច
នេះ មហារាជជាចម្រើន ការដែលត្រាស់ប្រើទូលបង្គំជាខ្ញុំឲ្យទៅក្រុងវិរាដ

បានសេចក្ដីដូចនេះមើលទៅមានអន្ទង់នៃសេចក្ដីបែកសាមគ្គីរវាងកោរពនឹង បាណ្ឌព អន្ទង់នេះនឹងសង់ស្ពានឆ្លង ដោយសេចក្ដីសំរួបសំរួមឲ្យស្ងប់សង្គ្រាមឲ្យរហូតទៅដល់ត្រើយមិនបាន ម្ដងនេះនឹងផ្សារឃើញជាមិនដិតហើយ ចិត្តយុធិស្ឋិរបំណងចង់បានតែអាណាចក្រពាក់កណ្ដាល សម្រាប់ខ្លួនគេដូចអំពីដើម ថាបើយើងមិនព្រមឲ្យគេ ក៏គង់កើតសង្គ្រាមកាប់សម្លាប់គ្នា ជាគ្រឿងវិនិច្ឆ័យក្នុងរឿងនេះ រកផ្លូវនឹងចៀសវាងមិនបាន ទូលព្រះបង្គំជាខ្ញុំបានឃើញកងទាហានខ្ទាប់ដែលពួកបាណ្ឌវ ត្រៀមទុក ព្រោះហេតុនោះ ដែលគេឲ្យមកគម្រាមយើង មិនមែនគម្រាមលេងទទេៗ ជាពាក្យស្រែករបស់គេមួយយ៉ាង ជាខុសឬត្រូវដូចម្ដេចក៏តាមតែការ ស្រេចគ្នាយកត្រង់កងទ័ពដ៏មានកម្លាំងនឹងវិនិច្ឆ័យ ឲ្យដាច់ស្រេចទៅ កាលបើដូចនោះ សេចក្ដីឃើញយ៉ាងជាន់ទាបៗ របស់ទូលបង្គំជាខ្ញុំថា គួរនឹងចៀសវាងការសង្គ្រាម កុំបីឲ្យកើតរឿងកាប់សម្លាប់គ្នានេះឡើយ ។

ព្រះចៅធ្ឫតរាស្ត្រត្រាស់ថា អ្នកពោលគាប់គួរហើយ យើងក៏មិនចូលចិត្តកាត់សេចក្ដីយ៉ាងព្រៃៗ យកកំហែងទល់នឹងកំហល់ យើងនឹងព្យាយាមឲ្យពេញកម្លាំង ដើម្បីរក្សាសេចក្ដីស្ងប់សាន្តត្រាណក្នុងប្រទេស ។

តាមបញ្ញាដែលយុធិស្ឋិរធ្វើទុក និងសញ្ញាយអំពីថ្ងៃមុន ទ្រង់ក៏បញ្ជូនក្រិស្ណ ទៅកាន់ក្រុងហស្តិនបុរ ដើម្បីសំរួបសំរួមសេចក្ដីវិវាទ នៃ

ព្រះញាតិវង្សទាំងសងខាង កាលមកដល់ក្រុងហស្តិនបុរ ព្រះចៅធ្ឫតរាស្ត្រ បានបដិសណ្ឋារ ទទាក់ទទួលយ៉ាងពេញកិត្តិយស មានសេចក្ដីគារវៈនិង ស្នេហាមេត្រី ប្រាស្រ័យទៅរកគ្នាដោយស្រួល ព្រោះក្រិស្ណ មិនគ្រាន់ តែជាក្សត្រិយ៍ ទ្រង់នូវមហិទ្ធិឫទ្ធិមួយយ៉ាងប៉ុណ្ណោះទាំងជាប់ខ្សែស្រឡាយ ជាញាតិវង្ស ១ អង្គផង ទ្រង់ប្រាស្រ័យនឹងក្រិស្ណថា ជាកិត្តិយសដ៏ខ្ពង់ ខ្ពស់ដែលទ្រង់បានស្ដេចយាងមកឋានសំណាក់ទូលបង្គំ ហើយទូលបង្គំ មានសេចក្ដីត្រេកអរពេញហឫទ័យ ដើម្បីទទួលស្គាល់ទ្រង់ជាពិតប្រាកដ ទូលបង្គំមិនដឹងបើនឹងយកពាក្យអ្វីមកសម្ដែងអំពីបីតិរបស់ទូលបង្គំបាន ។

ក្រិស្ណតបថា ខ្ញុំមកអំពីក្រុងវិរាដ ដើម្បីកិច្ចការរបស់បាណ្ឌវ ធ្ឫតរាស្ត្រទូលថា ដើម្បីអ្វីក៏តាមការ សូមឲ្យត្រាស់ចេញមកចុះ ទ្រង់ រមែងនាំសេចក្ដីបីតិប្រមោទ្យមកកាន់ក្រុងហស្តិនបុរជានិច្ច ទូលបង្គំមាន អំណរនឹងចាំស្ដាប់មធុរកថារបស់ទ្រង់ តែសញ្ជ័យទូតរបស់ទូលបង្គំ ទើប នឹងត្រឡប់អំពីរាជសំណាក់ វិរាដទូលបង្គំតោងពោលថា មិនសមប្រាថ្នា ក្នុងផ្លូវរាជការដែលគេទៅ គេទៅនិយាយបញ្ចុះបញ្ចូលផ្សះផ្សារការបែក បាក់គ្នា រវាងសាខានៃព្រះញាតិវង្សម្ដង ហើយមិនបានរួបរួមគ្នាជាស្រួល ទូលបង្គំពោលនេះតាមសេចក្ដីរាយការរបស់ទូត ដែលមកថ្វាយដល់ទូលបង្គំ កាលបើយុធិស្ឋិរមានបំណងចេតនានឹងធ្វើសង្គ្រាម គ្មានខាងណាលោះ លាត្រាប្រណី ក៏មុខជានឹងទង្គិចគ្នាម្ដងយ៉ាងខ្លាំង ទូលបង្គំយល់ថា

ប្រាកដថា កាលមានចិត្តក្រហល់ក្រហាយ ចង់តែស៊ីសាច់ហុត ឈាមគ្នា មាននៅដរាបណាការប្រឹក្សា ដើម្បីស្ងប់សឹករមែងធ្លាក់សូន្យ ទទេដរាបនោះ ដូចគ្រាប់ភ្លៀងដែលធ្លាក់លើផែនថ្មដ៏ក្តៅ ។

ក្រិស្ណា តបថា ខ្ញុំទឹកសន្ធិះ ពាក្យដែលទ្រង់ពោលមកនេះ ឃើញធ្លាយអំពីសេចក្តីដែលពិត ខ្ញុំដឹងជាការពិតថា យុធិស្ឋិរបានព្យាយាមគ្រប់ផ្លូវ ដើម្បីចៀសចាកការសង្គ្រាម ឱរសរបស់ទ្រង់ទៀត ជាអ្នកព្យាយាមស្វែងរកសឹកសាប់កាប់គ្នាដោយចិត្តពាលយង់ឃ្នង់ ការដែលយកសេចក្តីកំបិទកំបាំងក្នុងចិត្ត ទៅប្រហារអ្នកដទៃជាពងការវៀច មិនធ្លាប់ប្រាកដក្នុងចិត្តដ៏ត្រង់របស់យុធិស្ឋិរឡើយ ខ្ញុំមិនចង់នាំរឿងគំនិតខូចដែលធ្វើឲ្យអនាថបាណ្ឌព បានទទួលទណ្ឌកម្មមកហើយ ដោយតុណ្ហីភាពនោះទ រឿងលេងស្កាក្លាល់គ្នា ដោយឧបាយកលកោង រឿងគិតទិនផ្តាច់យកជីវិតគ្នា ទិន់រឹបអូសសម្បត្តិយកជាប្រយោជន៍ខ្លួន រឿងប្រមាថមើលងាយគ្នាក្នុងទីប្រជុំជន ទីនរឿងទុរាចារដែលបានធ្វើដល់ទ្រៅបទី ដោយគ្មានអាស្រ័យសម្បត្តិសេចក្តីលាមកអំពាលនេះ ជាខដំទៀល ស្ថិតនៅរហូតទៅ ធ្វើកេរ្តិ៍ឈ្មោះរបស់កុរុវង្សស្អុយរកទីបំផុតគ្មាន ត្រង់នេះតានរៃបរទៅអាស្រ័យកម្លាំងទាហាន ព្រោះគ្មានផ្លូវនឹងត្រឡប់ជាគ្នា គ្មានផ្លូវកែខៃ គ្មានផ្លូវនឹងផ្សះផ្សាឲ្យជាមេត្រីភាព គ្មានអ្វីនឹងយកមកលុបលាង អសត្យរបស់បងប្អូនឯងនេះបាន ទ្រព្យសម្បត្តិដែលបាត់ទៅ

អាចនឹងឃើញមកវិញបាន ក្តីឈ្មោះដែលខូច គឺខូចឈ្មោះថាខូចហួតនិវត្តកាល ពួកបាណ្ឌពបានទទួលទណ្ឌកម្ម ត្រាំត្រែងអាការបៀតបៀនអំបាលនេះ ដោយខន្តី ដោយសេចក្តីព្យាយាមក្លា នឹងមានមកអស់ការជាយូរហើយ ឥឡូវគេស្រែកសុំដោយសម្លុត មិនមែនជាការសែងសឹកយ៉ាងជ្រោកជ្រាក សុំទទួលសិទ្ធិមរតក ជំពូកភាគរបស់គេ ដោយត្រូវតាមច្បាប់ប៉ុណ្ណោះ មិនចង់បានរាជសម្បត្តិរបស់ទ្រង់ទេ គឺសុំតែដែនដីរបស់គេ ល្មមតែតាំងខ្លួនជាឥស្សរបាន ល្មមសមដល់ឋានៈជាក្សត្រិយ៍ ល្មមសមដល់ឋានៈជាមនុស្ស គេនឹងអាស្រ័យកិច្ចហារចិញ្ចឹមជីវិត យ៉ាងវណ្ណពួកព្រាហ្មណ៍ទាំងឡាយមិនបាន គង់មាមនៃមនុស្សជាតិ បាណ្ឌពខំសុំក្រោកឈរឡើង សុំសេចក្តីសុខម្តងទៀត នឹងស្រែកសុំយល់ពាសក្នុងរឿងច្បាំងកាប់សម្លាប់គ្នា ។

លំដាប់នោះក្រិស្ណ ក៏ស្តេចទៅតំណាក់ទុរយោធន៍ ដោយបំណងនឹងសំរួបសំរួមគ្នា ឲ្យគេយល់ផងតាមសេចក្តីឃើញរបស់ទ្រង់ដែលបំណងតែផ្លូវសុខ ទ្រង់ជ្រាបថា ទុរយោធន៍គ្របលើមនុស្សទាំងឡាយក្នុងរាជត្រកូលនោះទ្រង់ជ្រាបថាធ្លុតពន្រ្តា គ្មានសម្តីធំអ៊ីនឹងគេកងផ្លូវពជការស្រែកទេស ទ្រង់ជ្រាបថា គឺសក្យត្រិយ៍ពាស សូម្បីមានព្រះហឫទ័យបង្អោនទៅក្នុងផ្លូវស្ងាត់សុខ ក៏មិនអាចនឹងតបតនឹងទុរយោធន៍បានទ្រង់ជ្រាបថាទោណ កណ៌ នឹងគោរពទីប្រឹក្សាឯទៀត ក៏សុទ្ធតែជាខ្ញុំនៅក្នុងបង្គាប់

ទុរយោធន៍ទាំងអស់ទ្រង់មក ទ្រង់ព្រះចិន្តាឃើញថា បើទ្រង់និយាយ បង្អាក់ចិត្ត ទុរយោធន៍មិនឲ្យបាំងបាន ការលំបាករញីករញ៉ុកទាំងពួង ក៏ឈ្មោះថា បានសម្រេចស្រេចអស់តែពាក្យប្រឹក្សាសើរើរបស់ក្រិស្ណ មុខគួរនឹងបំពេញចិត្តទុរយោធន៍ឲ្យត្រជាក់ទន់ទៅរកផ្លូវស្ងប់ ត្រឡប់ទៅជារឿងបង្អាក់ទុរយោធន៍ឲ្យកើតមានរបិនរែងរូស អួតពូកែឡើងជាងមុន ទុរយោធន៍បែរព្រះភក្ត្រមកខាងក្រិស្ណហើយត្រាស់ថា ម្ដេចទ្រង់សម្ដែងអាការដិនធ្នូនឿយណាយនឹងខ្ញុំ ។

ក្រិស្ណតប ខ្ញុំជាមិត្រនឹងទ្រង់មិនខានដកប ទ្រង់នឹងត្រឡប់ចិត្តប្រព្រឹត្តប្រពៃ ក្នុងរវាងបាណ្ឌពជាគណៈញាតិរបស់ទ្រង់ ។

បញ្ចុះបញ្ចូលឲ្យទុរយោធន៍ត្រឡប់ចិត្តមកសម្រេច ក្រិស្ណក៏ស្ដេចទៅរកអ្នកដទៃ១តទៅទៀត ដែលធ្វើដូចនេះ បំណងនឹងរកឲ្យច្រើន១ ជួយទំរុតទំពេមសេចក្ដីយល់ឃើញរបស់ទុរយោធន៍ឲ្យសាយទៅ បានស្ដេចទៅរកវិទូរថ្លែងរឿងនោះតាមការ គេក៏មានសេចក្ដីស្ដាបក្នុងរឿងប្រឹក្សាការស្ងប់សឹកនោះដែរ ដោយឃើញស្រួលគ្រប់ផ្លូវត្រូវធម៌ គេទូលទ្រង់ថា ទុរយោធន៍ធ្វើស្បែតបិទត្រចៀកធ្វើមិនឮក្នុងរឿងស្រែកសុំ ដ៏ត្រឹមត្រូវតាមផ្លូវយុត្តិធម៌ ព្រោះចិត្តរបស់គេ គិតប៉ងតែនឹងសុំសាប់ប្រហាច់ឈាមឲ្យតាល់តែបាន បើទ្រង់កុំយាងមកកាន់ទីនេះសោះតែម្ដងល្អជាជាង ទុរយោធន៍មុខជានឹងមិនជឿស្ដាប់ពាក្យមនុស្សឯណានិមួយ មក

និយាយឲ្យតែខាតពេលទទេ ហាក់ដូចជានិយាយពោល កាលគេនិយាយសម្ដីអ្វីឡើង គេត្រូវការតែឲ្យមនុស្សក្នុងសកលលោកយល់តាមគេទាំងអស់ ។

គ្រិស្ណគប សេចក្ដីបំណងដោយចំពោះរបស់យើង គឺនឹងការពារមិនឲ្យកើតសឹកសង្គ្រាមប៉ុណ្ណោះ ដែលយើងខំមកកាន់ក្រុងហស្ដិនបុរទាំងនេះ ដើម្បីនឹងជួយពួកកុរុឲ្យរួចអំពីសេចក្ដីវិនាស ដែលគេស្វែងរកមកដាក់ខ្លួនគេ បើគេជឿស្ដាប់យើង គេកល់គ្នានឹងនៅជាសុខនិរភ័យ បើគេមើលងាយពាក្យណែនាំរបស់យើង គេនឹងបានសេចក្ដីវិនាសជារង្គាន់ ។

ថ្ងៃព្រឹកឡើង មានការប្រជុំរដ្ឋមន្ត្រីជាមហាសមាគមដោយឱកាសនោះ គ្រិស្ណបានចូលទៅនិយាយសំរួលសំរួមការស្ងប់សឹកម្ដងទៀត ក្នុងទីមហាសមាគម ត្រាស់នឹងព្រះធឫតរាស្ដ្រថា ខ្ញុំមកនេះមិនមែនជាមកស្វែងរកសង្គ្រាម មកដើម្បីទំរុតទំរេមរឿងសឹកសង្គ្រាម ឲ្យត្រឡប់មានមេត្តាស្នេហាគ្នាទៅវិញ មហារាជចូលទ្រង់កុំគាប់ចិត្តក្នុងអំពើអកុសល-ធម៌ ដ៏ជាគ្រឿងសៅហ្មងចិត្តនេះឡើយ ចូរលើកព្រះហស្តឡើងឲ្យពរជ័យសិរីសួស្ដីដល់ប្រទេស បំបាត់ឧបទ្រពភ័យដ៏មានកម្លាំង ដែលនឹងមកញាំញីយាយីរាជធានី និងព្រះរាជវង្សានុវង្សរបស់ទ្រង់ ចូរព្រមព្រៀងលើកផែនដីក្រុងឥន្ទ្របថឲ្យបាណ្ឌវក្សត្រិយ៍ តែដោយស្រួលទៅ តាម

ពាក្យសម្រែកស្រែកសុំដ៏ត្រូវតាមគន្លងធម៌ កុំធ្វើវីវរករឿងទឹងគេឡើយ
បើធ្វើបានដូចនេះសោត ប្រទេស របស់ទ្រង់នឹងរុងរឿងកិត្តិយសខ្ពស់មុខ
ប្រាសចាកសព្វភ័យ ល្បីនាមឮទៅ សុំឲ្យទ្រង់គិតមើល ប្រសិនបើ
ជាច្បាំងគ្នាទៅហើយ បណ្ដាក្សត្រិយ៍ចាញ់ស្លាប់អស់ក្នុងទីយុទ្ធភូមិសោត
តើទ្រង់នឹងបានអ្វីអំពីគេ ១ ទៀតការស្លាប់ដោយថ្វីដៃរបស់ទ្រង់ដូចនោះ
នឹងធ្វើឲ្យទ្រង់រីករាយសប្បាយព្រះហឫទ័យបានឬ គេជាព្រះពជនុរស
របស់ព្រះអនុជាធិរាជរបស់ទ្រង់មិនមែនឬ តែខ្ញុំសុំថ្លែងក្នុងទីប្រជុំជំសភា
នេះ សូមឲ្យជ្រាបថា ពួកបណ្ដាត្រៀមទុកព្រមស្រេច ដើម្បីនឹងច្បាំង
ហើយនឹងត្រៀម ដើម្បីស្ងប់សឹកស្មើគ្នា ទ្រង់នឹងសព្វព្រះហឫទ័យយកខាង
ចំបាំង ឬខាងស្ងប់ឈប់សឹកបានមួយរំពេច តែបើប្រសិនជាកើតចំបាំង
គ្នាឡើង ពួកចិត្តក្រនឹងចារឹកឡើងរឿងចំបាំងនោះទុកក្នុងពង្សាវតារ
តំណានាតាមលំអានរឿងពេញទៅដោយសេចក្ដីគ្មានសច្ចៈ ដឹងឬទេថា
ការសង្គ្រាមដូចនេះ ព្រះជាម្ចាស់លើឋានសួគ៌លោកហាម បើកាល
យានចុះកាន់សង្គ្រាមហើយ អ្នកណានឹងទំនាយបានថា នឹងចប់ចុះត្រឹម
មរណនៃបណ្ដាក្សត្រិយ៍ ឬត្រឹមអស់ពូជពង្សក្រុ កាលស្ដាប់ពាក្យសំរួប
សំរួមនៃក្រិស្ណសព្វទៅ ធ្ឫតរាស្ត្រទ្រង់ជាទុក្ខព្រួយព្រះហឫទ័យ ដោយ
ធម្មជាតទ្រង់ជាអ្នកមានធាតុខ្ទន់ តែត្រាស់តែខ្ញុំថា មិនដឹងបើនឹងធ្លាក់

ទៀតកែវ និងស្រាយកំណាចរបស់ទុរយោធន៍ម្ដេចបានទេ អស់ផ្លូវនឹងជួយជ្រោមជ្រែងហាមឃាត់បានហើយ ។

លំដាប់នោះភីស្មៈក្រោកឈរឡើង ថ្លែងសុន្ទរកថាជាសាំទៀនទុរ-យោធន៍តាមពាក្យណែនាំដ៏ប្រសើររបស់ក្រិស្ណ តែទុរយោធន៍ស្ដាប់ហើយៗ ក៏ស្ងៀមព្រងើយ ធ្វើហាក់ដូចជាមិនឮ តែកូនព្រះហឫទ័យក្ដៅក្ដួលស្ទើរស្រក់ព្រះលោហិត ។

ទោណ វិទូរ នាទេ និងអ្នកឯទៀតក្រៅអំពីនេះ មានសេចក្ដីឃើញយ៉ាងភីស្មៈ គឺដំណើរតាមភីស្មៈចូលមកអង្វរទុរយោធន៍ កុំឲ្យប្រកាន់អំណាចរាជសក្តិខ្លាំងពេក បេះតែផ្លាស់មុខគ្នាចូលមកអង្វរគេ ៗ គ្នាជាច្រើននាក់ ទុរយោធន៍នឹងព្រមអនុគ្រោះឲ្យគេលោមគទៅទៀតពុំបាន ទើបក្រោកឈរឡើងដំឡើងព្រះនេត្រក្រឡោតបំពើមក្រញូវគ្រោសថា ក្រិស្ណស្ដប់មុខយើង ស្រឡាញ់ពួកបាណ្ឌព ភីស្មៈធ្វើព្រះភក្ត្រតឹងខឹងនឹងយើង វិទូរនិងទោណដាក់មុខធ្ងន់ស៊ីឡឹងសំឡក់យើងដោយសំអប់ ព្រះរាជបិតាយើងសោត ក៏ទ្រង់ព្រះកន្សែងថ្លែងទុក្ខ រឿងបាបកម្មរបស់យើង និងត្អូញត្អែរ ដើម្បីឲ្យស្ងប់សឹកដែរ ដូច្នោះគេឃើញយើងធ្វើល្មើសអ្វីទៅហើយ ១ ទៀតបើបេះតែដូច្នេះ យើងជាក្សត្រិយ៍ទ្រង់នូវតេស្សរភាពនឹងលូកដៃទៅធ្វើអ្វីបាន លោកអ្នកធំទាំងឡាយអើយ សុំឲ្យលោកគិតមើលមួយរំពេចសិន បើយុធិស្ឋិរចូលចិត្តលេងល្បែងភ្នាល់ ហើយបានលេងស្កាភ្នាល់

ទាល់តែខ្ទុក ខូចបង់សម្បត្តិនិងឥស្សរភាពដោយគំនិតខ្លួន ម្តេចក៏មក
ពោះលោកគៀងយើងថាខូច កាលគេលេងក្អាល់លើកទីពីរបាញ់ហើយ ព្រម
ទទួលទោសនិរទេសដោយខ្លួនឯង ម្តេចគេមកហៅយើងថាចោរដតាកសី
របស់ហុណ្ឌរវេលានេះ ធ្លាក់ត្រូណាត់ត្រៃណាងទៅតាមយថាកម្មរបស់គេ
បក្សពួករបស់គេក៏មិនមានប៉ុន្មាននាក់ កម្លាំងរេហ៍ពលក៏មិនសូវមាំមួនមិន
ឈ្នះនឹងការប្រឡងជ័យ ខ្លួនយើងមិនធ្លាប់ក្រែងព្រះលើឋានសួគ៌ ហើយ
នឹងមកញញើតសម្តីគម្រាមរបស់មនុស្សប៉ិចប៉ុកទោចកំរនេះឬ ក្សត្រិយ៍
អាចនឹងស្លាប់ក្នុងទីប្រឡងសឹកក៏បាន តែមិនព្រមទទួលទោសចុះចាញ់អ្នក
ណា អ្នកប្រាជ្ញលោកពោលទុកដូចនេះ ក៏ឥឡូវនេះអញ្ជើញលោកព្រះ
ញាតិទាំងឡាយចូលស្តាប់ពាក្យខ្ញុំថ្លែងខ្លះវិញ ព្រះកាលបិតារបស់យើង
បានលើកអាណាចក្រឥទ្រូបជឲ្យទៅហុណ្ឌរ ក្នុងវេលាដែលទ្រង់កំពុង
វង្វេងស្រឡាញ់កូនក្មួយ ឬមិនដូច្នោះ ក៏ព្រោះទ្រង់ធ្លោយមិនខានជាតិឲ្យ
សព្វគ្រប់ ក្នុងផ្លូវកិច្ចការសម្រាប់ស្រុកទេស ជីវិតរបស់យើងមាននៅដ
រាបណា ពួកហុណ្ឌរ ក៏មិនគង់មិនបានជាម្ចាស់ខេត្តខណ្ឌសីមាឥទ្រូបជ
ទៀតជាដាច់ខាតដរាបនោះ រាជអាណាចក្រគួរនឹងមិនញែកជាពីរភាគ បាន
មករួមក្នុងផែនទីជាមួយគ្នាហើយ គង់រួមនៅដូចនេះរហូតនិរន្តរកាលទៅ
ពាក្យរបស់ខ្ញុំដែលពោលទៅនេះ ច្បាស់ណាស់ជាពាក្យមាំ គ្មានប្រឡំ
ត្រង់ណា មិនត្រឡប់ប្រែប្រួលជាពាក្យពីរទៅបាន ។

ក្រិស្ណក៏ជ្រាបហើយថា គ្មានប្រយោជន៍ក្នុងរឿងនេះ បើទុកជាលើកយកយុត្តិធម៌មកសំដិលសម្តែងយ៉ាងម្តេច ទុរយោធន៍ក៏គង់មិនយល់តាម ព្រោះមានទិស្ស័យរបើងគ្រាំនៅក្នុងសន្តាន តែដកបណាទៅមានឱកាសល្មមនិយាយ ក៏អន់និយាយមិនបាន គ្រានេះក៏ទៀត ក្រិស្ណត្រាស់ថា ទុរយោធន៍អើយ ម្តេចទ្រង់មិននិយាយដូចនេះបាន ម្តេចទ្រង់ភ្លេចបន់ត្រង់ដែលថា ទ្រង់នឹងមិនលើសទ្រើសគន្លងលើបងប្អូន ។

ទុហសាសន៍ថែរទៅខ្សឹបទូលទុរយោធន៍ពីបើមាត់ជាប្រញាប់ ដាស់តឿនរំឭកឲ្យដឹងខ្លួនថា ក្រែងកើតហេតុធំទៅបាន ដែលមកនឹងទទឹងអ្នកធំ អ្នកប្រាជ្ញជាច្រើនគ្នាក្នុងទីមហាសមាគម ទុរយោធន៍ បានស្តាប់ពាក្យអនុជទូលតឿន មិនទាន់បានតបឆ្លើយចួនសម្តី ក្រិស្ណក៏ក្រោកដើរចេញអំពីទីប្រជុំដ្ឋមន្ត្រី ព្រះកក្រុះឡើងក្រាលបណ្តាលឲ្យពោស ។

ព្រះកជាម្ចូតក្រស្តុបានពន្យល់ហេតុផលផ្សេងៗឲ្យឱរសមុខរីស្តាប់ម្តងទៀត ព្រះនាងគន្ធារីជននីជាទុរយោធន៍ ក៏យល់ឃើញតាមសម្តីមហារាជនោះដែរ តែពោះបីដូច្នោះទុរយោធន៍ក៏មិនផ្លាស់គំនិតក្រែងអ្នកណា ។

ក្រិស្ណឃើញថា សេចក្តីព្យាយាមរបស់ព្រះអង្គក្នុងទីផុតនេះរលំរលាយបង់ មិនសម្រេចប្រយោជន៍ដូចបំណង ក៏ស្តេចចេញពាកក្រុងហស្តិនបុរ ទៅដល់ក្រុងវិរាដ សារសព្វហេតុការណ៍ទាំងពួង ដែលប្រព្រឹត្តទៅក្នុងរាជសំណាក់កុរុ ឲ្យយុធិស្ឋិរស្តាប់តាមដំណើរគ្រប់ប្រការ ។

( នៅមានតទៅទៀត )

# សេចក្ដីស្រង់ធម៌ទេសនាយ៉ាងសង្ខេប

របស់លោកកុំម៉ង់ដង់ រូបែរ ដែលសម្ដែងនៅ

មន្ទីរពុទ្ធសាសនបណ្ឌិត្យ

កាលពីថ្ងៃ ១៨ សេតម ឆ្នាំ ១៩៣១

ក្រុមការ ជុំ-ម៉ៅ ប្រែជាភាសាខ្មែរ

---

១ ពិតមែនជាគេអាចថា និស្ស័យសន្ដាន ប៉ែកខាងបស្ចិមប្រទេស នឹងនិស្ស័យសន្ដានប៉ែកខាងបុព្វបូព៌ាប្រទេស មានជ្រោះជ្រៅធំកាត់ផ្ដាច់ពីគ្នា មិនអាចនឹងធ្វើស្ពានចួងពីទ្វីប ១ ទៅទ្វីប ១ បាន តែថាតាមដែលមានមនុស្សជាច្រើន បានស្រាវជ្រាវរកដោយសេចក្ដីព្យាយាមប្រឹងប្រែងទៅ នោះហាក់ដូចជាទ្វីបទាំង ២ នេះ អាចនឹងធ្វើឲ្យដឹងស្គាល់នូវនិស្ស័យសន្ដាន ទៅវិញទៅមកបាន ព្រោះថាក្នុងទ្វីបទាំង ២ នេះ សុទ្ធតែមានមនុស្ស ហើយមនុស្សទាំងនេះ ពិតមែនជាមានបែបភាពផ្សេងពីគ្នា ប៉ុន្តែសន្ដានខាងក្នុងមិនជាប្លែកគ្នាប៉ុន្មានទេឡើយ ។

ចំណែកខាងជាតិអឺរ៉ុបដែលនៅក្នុងបុព្វបូព៌ាប្រទេស មិនគួរនឹងនៅជាឯកឯងក្នុងនិស្ស័យសន្ដានរៀងខ្លួនទេ ត្រូវព្យាយាមល្បងមើល ដើម្បីឲ្យបានយល់ស្គាល់ធម្មជាតិដែលនៅជុំវិញខ្លួនជាដើម គឺថាអ្វីៗ ដែលមានសភាពជាមនុស្សនោះ ត្រូវកុំឲ្យកំបាំងពីយើង ហើយម្យ៉ាងទៀតសេចក្ដី

ដែលដឹងស្គាល់នេះ ជាប្រយោជន៍សម្រាប់ខ្លួនយើងផង ។ ទោះក្នុងស្រុកចិនក្តី ក្នុងស្រុកជប៉ុនក្តី ត្រូវតែគិតឲ្យបានស្គាល់និស្ស័យសន្តានរបស់មនុស្សទាំងពួងដែលយើងទុកជាកិច្ចប្រាស្រ័យ ទៅមក ។ សេចក្តីដែលពោលមកនេះ ជាប់ជំពាក់មកដល់យើងជាទម្ងន់ ព្រោះយើងជាប់កិច្ចនឹងនាំមនុស្សជាតិក្នុងដែនឥណ្ឌូសុីន ទៅកាន់សេចក្តីចម្រើនចុះបើយើងមិនបានស្គាល់និស្ស័យសន្តានរបស់ជាតិ ដែលយើងត្រូវដឹកនាំ តើកាលណានឹងបានញុំាងកិច្ចនេះ ឲ្យប្រព្រឹត្តស្រួលទៅបាន ។

ការដែលត្រូវឲ្យដឹងស្គាល់នូវនិស្ស័យសន្តានរបស់ជាតិក្នុងបូព៌ាប្រ - ទេសនោះ ត្រូវឲ្យមានធាតុផ្សេងៗ គឺហាត់រៀនភាសា សាកសួរគេទំនៀមទម្លាប់ប្រវេណីស្រុក ស្រាវជ្រាវរករឿងរ៉ាវនឹងសិក្សាវិធីសាសនា ។ ក្នុងធាតុទាំងប៉ុន្មានដែលបានពោលហើយនេះ យើងឃើញធាតុ ១ ដែលសំខាន់ជាងគេ គឺព្រះពុទ្ធសាសនា តែកាលណាសិក្សាទៅហើយ នឹងឃើញមានប្រយោជន៍យ៉ាងធំ ។

២- តើការសិក្សាព្រះពុទ្ធសាសនានេះ ជាការផុតនិស្ស័យ ដល់ជាតិក្នុងបស្ចិមប្រទេសឬអ្វី មិនមែនដូច្នោះឡើយ ដើម្បីនឹងឲ្យឃើញជាបន្ទាល់ នោះត្រូវតែពិនិត្យប្លោលៗនៃគោលធំៗរបស់ព្រះពុទ្ធសាសនា ធ្វើដូច្នេះទៅនឹងប្រទះឃើញថានិស្ស័យយើងអាចនឹងចាប់យកបាន ហើយ

ដូចកាលឃើញច្រើនតែត្រូវគ្នា និងវិធីក្បួនវិទ្យាសាស្ត្រទំនើបថ្មី ក្នុងប្រទេសអឺរ៉ុបផង ។

ឯគោលធំ ៗ ដែលយើងត្រូវពិនិត្យប្លោល ៗ នោះគឺ :

ក ) អំពីសេចក្ដីដែលមិនមានលក្ខណៈតម្រូវទុកជាមុន គឺថាមិនមានរបៀបតម្រូវជាដាច់ខាតថាត្រូវធ្វើដូច្នេះដូច្នោះឡើយ ។ ឯសេចក្ដីពិតនោះគេឃើញខ្លួនឯង គេនឹងជឿថាជាពិត លុះតែបានសង្កេតពិនិត្យហើយល្បងទៅឃើញច្បាស់ថាជាពិតមែន ។

ខ ) សេចក្ដីមិនទៀងនៃអាត្ម័នឬខ្លួនប្រាណ ៗ អាត្ម័នឬខ្លួនប្រាណឬអត្តភាពឬវិញ្ញាណ ដែលមនុស្សនិមួយៗមាន ដើម្បីរស់នៅ ដើម្បីរិះគិត និងដើម្បីសោយអារម្មណ៍នោះ សុទ្ធតែជាការប្រជុំនូវធាតុផ្សេងៗ ដែលជារូបធាតុនិងអរូបធាតុ មានកំណត់យ៉ាងខ្លីតែត្រឹម ១ ជាតិមនុស្សប៉ុណ្ណោះ តែមានធាតុណា ១ ខ្លះហើយ ប្រជុំធាតុទាំងអស់នឹងរលត់ទៅផង ដូច្នេះឃើញថារូបនេះមិនមានខ្លឹមសារនិងហាំរបិតថេរឡើយ ។ តើអ្វីដែលទ្រទ្រង់នូវហេតុរបស់ទុក្ខក្នុងលោកនេះ មានរោគាព្យាធិសេចក្ដីស្លាប់និងសេចក្ដីទុក្ខព្រាត់ប្រាសចាកញាតិសន្ដានមិត្រសំឡាញ់ជាដើម គឺវិញ្ញាណរបស់យើងរាល់គ្នាប្រសិនវិញ្ញាណនេះមិនជាធំ មិនមានសេចក្ដីសំខាន់ទេ នោះជីវិតក៏នឹងបាត់នូវប្រយោជន៍ហើយសេចក្ដីស្លាប់នោះ ក៏

គ្រាន់តែជាបាបគ្រោះអ្វីម្យ៉ាង ៗ ប៉ុណ្ណោះ ព្រោះថា សេចក្ដីស្លាប់ហាក់ដូចជាទៅចាប់ នូវវិញ្ញាណ ១ ដែលមិនមានទោស ។

ក ) អំពីកម្មឬបច្ច័យរបស់ហេតុនិងផល អំពើនិមួយៗតែងបង្កើតឡើងនូវផល វិធីត្រង់នេះជាការពិបាកនិងរិះគិតបន្តិច មិនថាតែយើងដែលជាជាតិនៅក្នុងបស្ចិមប្រទេសឡើយ ទោះជាតិដែលនៅក្នុងបស្ចិមប្រទេសក្ដី ក៏បានសេចក្ដីពិបាកដូចគ្នា ព្រោះថាសម្បាលដល់ព្រះសម្មាសម្ពុទ្ធ ម្ដេចក៏ព្រះអង្គគង់សម្ដែងថា ជាការពិបាកនឹងរិះគិតពេកណាស់ អំពីបដិច្ចសមុប្បាទធម៌ ដែលជាធម៌មានបច្ច័យទាក់ទងនៃហេតុនិងផល ។

ប៉ុន្តែគេអាចនឹងទាញគំនិតដាក់ឲ្យជិតដោយងាយបាន គឺថាតែការពិចារណាឲ្យជ្រៅទៅ សេចក្ដីលំបាកក៏នឹងលេចផុសឡើង សេចក្ដីនេះគ្រាន់តែជាប្រស្នាធម្មតា អំពីនិស្ស័យនិងផលដែលឥតរូបឬមានរូបប្រាកដនៃអំពើរបស់យើង ដែលជាក្រសែផ្ទាល់ពីយើងឬមិនផ្ទាល់ គួរយើងសម្គាល់ម្យ៉ាងទៀតថាក្នុងប្រទេសអឺរុប ប្រស្នាអំពីនិស្ស័យនេះ គេបានរិះគិតជាអនេកប្បការ ហើយសេចក្ដីវិនិច្ឆ័យអំពីប្រស្នានេះ នៅមានមន្ទិលសង្ស័យជាច្រើននៅឡើយ តែថាបើគេរកមិនឃើញដោយច្បាស់ប្រាកដគ្រឿងខ្លះរបស់និស្ស័យនេះ នោះត្រូវតែពិនិត្យនូវផលដែលបណ្ដាលឡើង ។

ប៉ុន្តែព្រះពុទ្ធសាសនាតែងខ្វនូវនិស្ស័យ ដោយអំណាចផ្លូវចិត្តជា

កណ្តាល មនុស្សម្នាក់ដែលបានស្គាល់ច្បាស់នូវធម៌ដែលគ្រប់គ្រងលោក ដោយអំណាចសេចក្តីព្យាយាមរបស់ខ្លួន នោះអាចនឹងជម្នះនូវនិស្ស័យ ដែលជាប់តមកបាន ។ ក្នុងស្ថាននេះក៏ដោយ មិនមានគូដែលជាទីទទឹងទាស់នឹងគំនិតយើងជាតិអឺរ៉ុបឡើយ ។

ឃ- អំពីព្រះនិព្វាន ពិតមែនជាគេបានពោលមកហើយថា ព្រះនិព្វានជាអាការដែលប្រាសចាកភព ដែលដាច់ផុតអំពីវិញ្ញាណបដិសន្ធិ ដែលស្គាល់ច្បាស់នូវធម៌សម្រាប់លោក តែថាមិនមែនជាសេចក្តីសូន្យនោះទេ គឺជាតួឈានមួយយ៉ាងដាច់ខាតមានសភាពប្រហែលគ្នានឹងឈាន យ៉ាងតឹងរបស់ពួកព្រះអរហន្តខាងសាសនាក្រេះចៀង ដែលវេលាចេញពីឈានមកវិញ រកពាក្យនិយាយមិនត្រូវ អំពីលេលបានឃើញនឹងបានសោយអារម្មណ៍ក្នុងវេលាចូលឈាននោះ ។ ចំណែកខាងព្រះនិព្វានក៏មានស្ថានដូចគ្នាដូច្នេះដែរ ។

ជាមុននឹងបញ្ចប់សេចក្តី ខ្ញុំសូមអធិប្បាយ ២ ម៉ាត់ទៀតអំពីពាក្យដែលគេតែងពោលថាព្រះពុទ្ធសាសនានាំឲ្យខ្លាច នឹងនាំឲ្យព្រងើយកន្តើយមិនមែនជាដូច្នោះឡើយ គឺជាលទ្ធិសាសនា ដែលនាំឲ្យមានសេចក្តីព្យាយាមយ៉ាងមាំមួន ។ មិនមែនហៅថាខ្លាចទេ ដែលបានស្គាល់សេចក្តីលំបាកក្នុងការដែលនឹងធ្វើសង្គ្រាម ហើយមិនរួញរាត្រឡប់ជាបម្រុងខ្លួនតយុទ្ធនឹងខ្មាំងសត្រូវវិញ ។